ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

**ជូនចំពោះ**
**លោកស្រី ឯក ច័ន្ទដានី ប្រធានការិយាល័យពិធីការ និងបដិសណ្ឋារកិច្ច**
**និងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីសោកស្តាយ ញ្ជួយចិត្តក្រៃលែង ដោយបានទទួលដំណឹងថា ឧបាសក **ហេង ស៊ុនឡុង** ដែលត្រូវជាឪពុកបង្កើត លោកស្រី ឯក **ច័ន្ទដានី** ប្រធានការិយាល័យពិធីការ និងបដិសណ្ឋារកិច្ច នៃនាយកដ្ឋានរដ្ឋបាល និងសរុប នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានទទួលមរណភាពកាលពីថ្ងៃព្រហស្បតិ៍ ១កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៧ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១២:០០នាទីវេលងអធ្រាត្រ ក្នុងជន្មាយុ៧២ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ ក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាអនេកប្បការ ជាមួយលោកស្រី និងក្រុមញាតិគ្រួសារ ចំពោះការបាត់បង់ឧបាសក **ហេង ស៊ុនឡុង** ដែលត្រូវជាឪពុក និងជីតាដែលជាទីគោរពស្រលាញ់របស់ខ្លួន។

ខ្ញុំសូមឧទ្ទិសបួងសួងជូនដួងវិញ្ញាណក្ខន្ធ ឧបាសក **ហេង ស៊ុនឡុង** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកស្រី និងក្រុមគ្រួសារ** មេត្តាទទួលនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃ សុក្រ ២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

ព្រុំ សុខា